00645571

E51/2

# ក្រុមមេធាវីការពារក្តី អៀង សារី
# IENG SARY DEFENCE TEAM
# EQUIPE DE DEFENSE DE IENG SARY

ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១១

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 17 / 02 / 2011
ម៉ោង (Time/Heure): 14:50
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

ជូន: លោកស្រី Susan LAMB
មន្ត្រីច្បាប់ជាន់ខ្ពស់ នៃ អង្គជំនុំជម្រះសាលាដំបូងនៅ អវតក

ចម្លងជូន អង្គជំនុំជម្រះសាលាដំបូង នៅ អវតក
ក្រុមមេធាវីការពារក្តី នៅ អវតក
អង្គភាពគាំពារការការពារក្តី នៅ អវតក
ការិយាល័យសហព្រះរាជអាជ្ញា នៅ អវតក
មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី នៅ អវតក ក្នុងសំណុំរឿង ០០២

កម្មវត្ថុ នីតិវិធីដែលបានធ្វើវិសោធនកម្មរបស់អង្គជំនុំជម្រះសាលាដំបូងសម្រាប់ដាក់អញ្ញត្រកម្ម និងការបញ្ជាក់ពីការកំណត់នៃការឆ្លើយតប

មកដល់លោកស្រី Susan LAMB ជាទីរាប់អាន

កាលពីថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១១ លោកស្រី បានផ្ញើលិខិតមួយច្បាប់ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១១ ទៅឱ្យភាគីទាំងអស់ក្នុងសំណុំរឿង ០០២ ។ លិខិតនោះ មានចំណងជើងថា "នីតិវិធីដែលបានធ្វើវិសោធនកម្មរបស់អង្គជំនុំជម្រះសាលាដំបូង សម្រាប់ដាក់អញ្ញត្រកម្ម និងសេចក្តីបញ្ជាក់ពីការកំណត់នៃការឆ្លើយតប" ("លិខិត") ។ យើងខ្ញុំមានការបារម្ភទាក់ទងនឹងខ្លឹមសារក្នុងលិខិតរបស់លោកស្រី[1] ។

[1] *ករណីលោក* អៀង សារី, សំណុំរឿងលេខ ០០២-១៩-០៩-២០០៧- អវតក/អជសអ, អនុស្សារណៈអន្តរការិយាល័យពីលោកស្រី Susan Lamb អ្នកពិគ្រោះយោបល់ផ្នែកច្បាប់ជាន់ខ្ពស់ នៅ អជសអ ផ្ញើរជូន ភាគីទាំងអស់ក្នុង សំណុំរឿង ០០២, ក្រោមចំណងជើងថា នីតិវិធីដែលបានធ្វើវិសោធនកម្មរបស់អង្គជំនុំជម្រះសាលាដំបូង សម្រាប់ដាក់អញ្ញត្រកម្ម និងសេចក្តីបញ្ជាក់ពីការកំណត់នៃការឆ្លើយតប ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១១, ឯកសារលេខ E51, ERN: 00644105-00644106។

**លិខិតដដែលនោះ លើកឡើងថា អង្គជំនុំជម្រះសាលាដំបូង នឹងមិនចាត់ទុកជនជាប់ចោទជាបុគ្គលដោយឡែកឡើយ**

លោកស្រី បានគូសបញ្ជាក់ថាអង្គជំនុំជម្រះ បានដឹងថាអញ្ញត្រកម្មជាច្រើន គឺដូចគ្នា និងជាន់គ្នា។ លោកស្រីហាក់បីដូចជាបានស្នើឱ្យជនជាប់ចោទទាំងបួន ធ្វើការរួមគ្នាជាក្រុមក្នុងការដាក់សារណាជាក្រុម ។ នេះមិនមែនជាលិខិតឆ្លងឆ្លើយលើកទី១ទេដែលលោកស្រីបានធ្វើសំណើបែបនេះ[2]ទេ។ ចំណុចនេះគឺផ្ទុយគ្នាទៅនឹងទស្សនៈដែលបានបង្កើតយ៉ាងត្រឹមត្រូវថា ជនជាប់ចោទទាំងឡាយ ត្រូវទទួលបានសិទ្ធិទទួលបានការប្រព្រឹត្តមកលើក្នុងលក្ខណៈជាបុគ្គលម្នាក់ដាច់ដោយឡែក។ ខណៈដែលវាអាចមានលក្ខណៈងាយស្រួលសម្រាប់ កសព និង អង្គជំនុំជម្រះសាលាដំបូង បើសិនជាជនជាប់ចោទទាំងបួននាក់ ដាក់សារណារួមគ្នា បញ្ហាដែលនៅតែមាននោះគឺថា ជនជាប់ចោទម្នាក់ៗ មានក្រុមមេធាវីការពារក្តីរៀងៗខ្លួន មានការណែនាំរៀងៗខ្លួន និងប្រកាន់យកនូវវិធីសាស្ត្ររៀងៗខ្លួន។ ការប្រព្រឹត្តមកលើជនជាប់ចោទម្នាក់ក្នុងនាមជាបុគ្គលឯកជនដាច់តែឯង គឺមានចែងដោយរដ្ឋធម្មនុញ្ញកម្ពុជា ដែលចែងថា ពលរដ្ឋខ្មែរទាំងឡាយត្រូវតែបានគេប្រព្រឹត្តមកលើក្នុងនាមជាបុគ្គលឯកជន នៅចំពោះមុខច្បាប់ មិនមែនជាសមូហភាពឡើយ[3]។ សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស (“UDHR”) ដែលត្រូវតែបានគេគោរពនៅកម្ពុជា ដោយអនុលោមទៅតាមរដ្ឋធម្មនុញ្ញកម្ពុជា[4] ក៏ចែងផងដែរថា បុគ្គលម្នាក់ត្រូវតែបានគេប្រព្រឹត្តមកលើក្នុងលក្ខណៈជាបុគ្គលឯកជននៅចំពោះមុខច្បាប់ មិនមែនជាលក្ខណៈសមូហភាពឡើយ[5]។

**លិខិតនេះ បានដកចៅក្រមខ្មែរមិនឱ្យចូលរួមដោយពេញលេញក្នុងការពិភាក្សាសម្រេចអំពីអញ្ញត្រកម្ម**

---

[2] “អង្គជំនុំជម្រះសាលាដំបូង ជម្រុញឱ្យក្រុមមេធាវីការពារក្តីសំរបសម្រួលសំណើរបស់ពួកគេនៅពេលណាដែលអាចធ្វើទៅបាន ហើយក្នុងករណីដែលមានយុត្តិសាស្ត្រដូចគ្នាត្រូវដាក់សំណើសុំរួមគ្នាតែមួយនៅចំពោះមុខអង្គជំនុំជម្រះ។ *ករណីលោក* អៀង សារី, សំណុំរឿងលេខ ០០២-១៩-០៩-២០០៧- អវតក/អជសដ, អនុស្សារណៈអន្តរការិយាល័យពីលោកស្រី Susan Lamb អ្នកពិគ្រោះយោបល់ផ្នែកច្បាប់ជាន់ខ្ពស់ នៅ អជប ផ្ញើរជូន ភាគីទាំងអស់ក្នុង សំណុំរឿង ០០២, សេចក្តីជូនដំណឹងជាមុនរបស់សេចក្តីសម្រេចរបស់អង្គជំនុំជម្រះលើពាក្យសុំលេខ E14, E15, E9/2, E9/3, E/24 and E27, ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១១, ឯកសារលេខ E35, ERN: 00642291-00642292។

[3] មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជា ដែលបានធ្វើវិសោធនកម្មក្នុងឆ្នាំ ១៩៩៩ ចែងក្នុងផ្នែកពាក់ព័ន្ធថា "ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់"។ (គូសបញ្ជាក់បន្ថែម)

[4] មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជា ដែលបានធ្វើវិសោធនកម្មក្នុងឆ្នាំ ១៩៩៩ ចែងក្នុងផ្នែកពាក់ព័ន្ធថា “ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ”។

[5] មាត្រា ៦ UDHR ចែងថា “មនុស្សគ្រប់រូបមានសិទ្ធិអោយគេទទួលស្គាល់នៅគ្រប់ទីកន្លែង ថាជាបុគ្គលម្នាក់នៅចំពោះមុខច្បាប់”។

លោកស្រីបានគូសបញ្ជាក់ថា អញ្ញត្រកម្មជាច្រើនបានលើកឡើងពីមន្ទិលសង្ស័យទាក់ទងនឹងបញ្ហាថាតើអញ្ញត្រកម្មទាំងនេះទាក់ទងបញ្ហាយុត្តាធិការ និងថាតើអញ្ញត្រកម្មទាំងនេះ អាចទទួលយកបានដែរឬអត់។ លោកស្រីបានគូសបញ្ជាក់ថាលោកស្រីនឹងជូនដំណឹងដល់ភាគីថាតើការដាក់ឯកសារទាំងនេះ ឬផ្នែកណាមួយនៃការដាក់ឯកសារទាំងនេះ ត្រូវបានពិចារណាមិនអាចទទួលយកបានថាជាអញ្ញត្រកម្មនៅត្រឹមថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១១។ លោកស្រី បានបង្គាប់ឲ្យអង្គភាពបកប្រែ(ITU) ផ្អាកការបកប្រែអញ្ញត្រកម្មដែលនៅសល់ទាំងអស់ទៅជាភាសាខ្មែរ ។ នៅពេលដែលអង្គជំនុំជម្រះសាលាដំបូងទទួលបានតែអញ្ញត្រកម្មមួយចំនួនតែជាភាសាអង់គ្លេស និងបារាំង នោះសេចក្ដីសម្រេចទាក់ទងនឹងភាពអាចទទួលយកបាននៃអញ្ញត្រកម្ម អាចត្រូវបានធ្វើឡើងតែដោយចៅក្រមអន្តរជាតិតែប៉ុណ្ណោះ។

គោលបំណងនៃការដាក់អញ្ញត្រកម្មទាំងភាសាអង់គ្លេស និងភាសាខ្មែរ គឺដើម្បីឲ្យទាំងមេធាវី និងចៅក្រមជាតិ ព្រមទាំងចៅក្រម និងមេធាវីអន្តរជាតិ អាចធ្វើសេចក្ដីសម្រេចប្រកបដោយវិរិយភាពលើអញ្ញត្រកម្មទាំងនេះ ។ ការបកប្រែក៏ដើរតួនាទីជាឧបករណ៍អប់រំសម្រាប់អ្នកច្បាប់កម្ពុជាក្មេងៗ និងប្រជាជនកម្ពុជាទាំងមូលផងដែរ ដូច្នេះការបកប្រែភាសា នឹងជួយជ្រោមជ្រែងដល់កេរ្តិ៍ដំណែលរបស់ អវតក ។ លិខិតនេះអនុវត្តផ្ទុយនឹងគោលការណ៍ទាំងនេះ។

**លិខិតនេះ រំលោភសិទ្ធិរបស់លោក អៀង សារី ក្នុងការទទួលបានមធ្យោបាយគ្រប់គ្រាន់ដើម្បីត្រៀមរៀបចំការការពារក្ដីរបស់គាត់**

លោកស្រីបានបង្គាប់ឲ្យភាគីទាំងអស់ដាក់ឯកសាររួមដែលមានគម្រោងដាក់អញ្ញត្រកម្មត្រឹមថ្ងៃសុក្រ ទី២៥ ខែកុម្ភៈ ឆ្នាំ២០១១ ជាភាសាអង់គ្លេស ឬភាសាបារាំង ហើយបន្ទាប់មកដាក់ជាភាសាខ្មែរតាមក្រោយឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន។ មូលហេតុដែលធ្វើដូច្នេះ គឺដើម្បីផ្ដល់លទ្ធភាពឲ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការវាយតម្លៃជាបឋមអំពីចំនួន វិសាលភាព និងសារៈសំខាន់នៃអញ្ញត្រកម្មទាំងអស់។

វិសាលភាព និងសារៈសំខាន់នៃអញ្ញត្រកម្ម មិនអាចត្រូវបានកំណត់តាមរយៈការធ្វើបញ្ជីខ្លីៗនោះឡើយ។ ភាពអាចទទួលយកបាននៃអញ្ញត្រកម្ម ក៏មិនអាចត្រូវបានសម្រេចតាមរយៈការធ្វើបញ្ជីខ្លីៗបានដែរ។ អញ្ញត្រកម្មភាគច្រើន គឺមានការជំទាស់ខាងយុត្តាធិការយ៉ាងស្មុគស្មាញ។ អញ្ញត្រកម្មនីមួយៗត្រូវការពេលវេលាដើម្បីធ្វើការវិភាគ និងដើម្បីផ្ដល់នូវសេចក្ដីសម្រេចមួយដែលមានសំអាងហេតុ។ ការអះអាងថាអង្គជំនុំជម្រះសាលាដំបូង នឹងធ្វើការវាយតម្លៃជាបឋមមុនពេលមានសារណាលម្អិត (ដែលប្រហែលជាមិនអាចធ្វើបានលុះត្រាតែស្នើសុំដោយអង្គជំនុំជម្រះផងនោះ) បានរំលោភដល់សិទ្ធិរបស់លោក អៀង សារី

ក្នុងការទទួលបាននូវមធ្យោបាយគ្រប់គ្រាន់ដើម្បីត្រៀមរៀបចំការការពារក្ដីរបស់គាត់[6]។ អង្គជំនុំជម្រះសាលាដំបូង គឺមិនបានកំពុងអនុវត្តតួនាទីរបស់ខ្លួនឱ្យបានត្រឹមត្រូវឡើយដោយរំលោភលើក្រមសីលធម៌ចៅក្រមនៅ *អវតក*[7] ។ ចំពោះអង្គបុរេជំនុំជម្រះ ដែលកំពុងធ្វើសេចក្ដីសម្រេចភាគច្រើនលើការជំទាស់ខាងយុត្តាធិការដ៏ស្មុគស្មាញនេះផងដែរនោះ បញ្ហាទាំងនេះលើកឡើងនូវ "ចំណុចដែលពីមុនមកមិនត្រូវបានលើកឡើងនៅចំពោះមុខតុលាការជាតិ ហើយក្នុងករណីជាច្រើន ចំណុចនេះកាលពីមុនមិនដែលត្រូវបានគេយកទៅពិចារណាក្នុងច្បាប់អន្តរជាតិឡើយ ជាពិសេសនៅក្នុងបរិបទពេលវេលានៅ *អវតក*... សិទ្ធិរបស់ភាគីនឹងត្រូវប៉ះពាល់យ៉ាងធ្ងន់ធ្ងរដោយសារការខកខានមិនបានវាយតម្លៃ និងដោះស្រាយឱ្យបានត្រឹមត្រូវនិងយកចិត្តទុកដាក់នូវបញ្ហាទាំងអស់ដែលបានលើកឡើង[8]" ។

**លិខិតនេះ រំលោភសិទ្ធិមេធាវីការពារក្ដីក្នុងការបង្កើតកំណត់ត្រា**

មកទល់ពេលនេះ លោកស្រីមានឯកសារថតចម្លងអំពីអញ្ញត្រកម្មទាំង៨របស់ពួកយើង។ មានតែអញ្ញត្រកម្ម ២ក្នុងចំណោមអញ្ញត្រកម្មទាំង៨នេះប៉ុណ្ណោះ ត្រូវបានដាក់ជាផ្លូវការជាពីរភាសា ហើយមានតែអញ្ញត្រកម្ម១ប៉ុណ្ណោះដែលត្រូវបានជូនដំណឹងជាផ្លូវការ[9]។ យើងខ្ញុំអាចដាក់ឯកសារតែពេលណាដែលយើងមានឯកសារ

---

[6]មាត្រា ១៣ (១) នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ធានាថាសិទ្ធិរបស់ជនជាប់ចោទដែលមានចែងនៅក្នុងមាត្រា ១៤ និងមាត្រា ១៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពី សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) ត្រូវបានគោរពនៅទូទាំងដំណើរការនៃការជំនុំជម្រះក្តី ។ សិទ្ធិបែបនេះជាពិសេសរួមមាន... សិទ្ធិមានពេលវេលា និងលក្ខណៈគ្រប់គ្រាន់ ដើម្បីត្រៀមរៀបចំការពារខ្លួន និងសិទ្ធិទំនាក់ទំនងជាមេធាវីតាមការជ្រើសរើសដោយខ្លួនឯង" ។ មាត្រា ៣៥ថ្មីនៃច្បាប់បង្កើត *អវតក* ចែងក្នុងផ្នែកពាក់ព័ន្ធថា "ក្នុងការចោទប្រកាន់មកលើខ្លួន ជនជាប់ចោទមានសិទ្ធិទទួលបាននូវការធានាជាអប្បបរមានិងស្មើៗ គ្នាស្របតាមមាត្រា១៤ នៃអនុសញ្ញាអន្តរជាតិស្តីពិសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ...(ខ)<u>មានពេល វេលា និងលក្ខណៈគ្រប់គ្រាន់ដើម្បីរៀបចំការពារខ្លួន និងទាក់ទងជាមួយមេធាវីដែលខ្លួនជ្រើសរើស ដោយខ្លួនឯង</u>" មាត្រា ១៤(៣) នៃកតិកាសញ្ញាអន្តរជាតិស្តីពី សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ "ក្នុងការសម្រេចសេចក្តីចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួន ជនគ្រប់រូបមាន សិទ្ធិទទួលបានការធានាជាអប្បរិមាដោយស្មើភាពគ្នាយ៉ាងពេញលេញ៖ ... (ខ)ត្រូវមាន<u>ពេលវេលានិងសម្ភារៈរូបវត្ថុគ្រប់គ្រាន់សម្រាប់រៀបចំការពារខ្លួន និងឆ្លើយឆ្លងជាមួយមេធាវីដែលជ្រើសរើស ដោយខ្លួនឯង</u>...។

[7] ក្រមសីលធម៌ចៅក្រមនៅ *អវតក* ដែលបានធ្វើវិសោធនកម្មនៅថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០០៨ មាត្រា ៥ ចែងមួយផ្នែកថា "១. ចៅក្រមត្រូវបំពេញតួនាទីភារកិច្ចរបស់ខ្លួនដោយសេចក្តីសង្វាតព្យាយាម និងប្រើសមត្ថភាពវិជ្ជាជីវៈរបស់ខ្លួនដើម្បីបំពេញភារកិច្ចទាំងនោះ ៣. ចៅក្រមត្រូវបំពេញគ្រប់តួនាទីភារកិច្ចរបស់ខ្លួនអោយបានឆាប់រហ័ស និងត្រឹមត្រូវ" ។

[8] *ករណី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក, អនុស្សរណៈអន្តរការិយាល័យពីអង្គបុរេជំនុំជម្រះឆ្លើយតបទៅនឹងអនុស្សរណៈអន្តរការិយាល័យពីអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១១, ចុះថ្ងៃទី ៩ កុម្ភៈ ២០១១ ឯកសារ D427/1/28 ERN: 00641791-00641796 នៅទំព័រទី២ ។

[9] *ករណី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក, អញ្ញត្រកម្ម ៨៩(១) របស់ អៀង សារី (អជ្ញាយុកាលនៃ

E51/2

ជាភាសាអង់គ្លេស និងភាសាខ្មែរ ។ លោកស្រី បានបង្គាប់ឱ្យអង្គភាពបកប្រែផ្អាកការបកប្រែអញ្ញត្រកម្ម ដែលនៅសល់ទាំងអស់ទៅជាភាសាខ្មែរ ។ លោកស្រីបានគូសបញ្ជាក់ថាលោកស្រីនឹងជូនដំណឹងដល់ភាគី ដាក់ឯកសារ ឬអំពីការដាក់ឯកសារណាមួយដែលមិនអាចទទួលយកបានជាអញ្ញត្រកម្ម ត្រឹមថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ២០១១ ។ ប្រសិនបើលោកស្រីសម្រេចថាអញ្ញត្រកម្មណាមួយរបស់ពួកយើងមិនអាចទទួលយក បានទេនោះ យើងមិនអាចដាក់អញ្ញត្រកម្មនោះបានទេ ។ ករណីនេះ បានរារាំងយើងខ្ញុំមិនឱ្យធ្វើ កំណត់ត្រាអំពីអញ្ញត្រកម្មពិសេសនោះ ទោះបីជាវាត្រូវបានគេសម្រេចរួយហើយក៏ដោយ ។ ការកត់ត្រាទុក នូវអញ្ញត្រកម្មរបស់យើង នឹងធ្វើឱ្យអ្នកធ្វើសេចក្តីសម្រេចនៅថ្ងៃអនាគតយល់ថាតើការដាក់ឯកសារអ្វីខ្លះ ដែលត្រូវបានធ្វើឡើងដោយយើងខ្ញុំ ហើយសកម្មភាពអ្វីខ្លះដែលត្រូវបានធ្វើឡើងដោយអ្នកទទួលឯកសារពី យើងខ្ញុំ។ ក្នុងករណីដាក់អញ្ញត្រកម្មបឋម ការកត់ត្រាទុកនឹងពន្យល់អ្នកធ្វើសេចក្តីសម្រេចនៅថ្ងៃ អនាគតថា យើងត្រូវបានគេជំទាស់យ៉ាងប្រុងប្រយ័ត្នបំផុត នូវរាល់បញ្ហាយុត្តាធិការទាំងអស់នៅចំពោះមុខអង្គជំនុំជម្រះ សាលាដំបូង ។

អាស្រ័យលើមូលហេតុដូចដែលបានគូសបញ្ជាក់ក្នុងលិខិតនេះ យើងស្នើឱ្យអង្គជំនុំជម្រះសាលាដំបូងកុំចាត់ ទុកជនជាប់ចោទទាំង៤ ជាបុគ្គលតែម្នាក់ ហើយសូមឱ្យអង្គជំនុំជម្រះសាលាដំបូង ទទួលយកអញ្ញត្រកម្ម ទាំងអស់ និងពិចារណាអញ្ញត្រកម្មនោះឱ្យបានពេញលេញមុនពេលធ្វើសេចក្តីសម្រេចណាមួយ។

**អាង ឧត្តម** Michael G. KARNAVAS

សហមេធាវីរបស់លោក **អៀង សារី**